អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# សេចក្តីប្រកាសព័ត៌មាន
# របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង

សេចក្តីប្រកាសព័ត៌មានជាសាធារណៈនេះ ត្រូវបានធ្វើឡើងដោយអនុលោមតាមវិធានផ្ទៃក្នុង ២១(១)(គ) របស់ អ.វ.ត.ក ដើម្បីធានាថា សាធារណជន ជាពិសេស ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត ត្រូវបានទទួលព័ត៌មានក្នុងថិរវេលាសមស្រប អំពីដំណើរការនីតិវិធីដែលកំពុងបន្តរបស់ អ.វ.ត.ក។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានស្បថចូលកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតបម្រុង នៅចំពោះមុខកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។ ដោយអនុលោមតាមកិច្ចព្រមព្រៀងដែលត្រូវបានចុះហត្ថលេខាដោយរាជរដ្ឋាភិបាលកម្ពុជា នឹងអង្គការសហប្រជាជាតិ និងច្បាប់គ្រប់គ្រងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង មានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការស៊ើបអង្កេតសំណុំរឿងដែលត្រូវបានបញ្ជូនមកពីការិយាល័យសហព្រះរាជអាជ្ញា [មាត្រា ៥(៦) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ១២ ២៣ ២៦ ២៧ និងមាត្រាផ្សេងទៀតនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង មានសិទ្ធិស្របច្បាប់ពេញលេញក្នុងការបំពេញមុខងាររបស់ខ្លួន ទោះបីជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានបដិសេធមិនធ្វើការតែងតាំងរូបលោក ជាសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិក៏ដោយ។ ចាប់តាំងពីបានចូលរួមជាមួយ អ.វ.ត.ក នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១ លោកបានចាត់វិធានផ្សេងៗដើម្បីធានាឲ្យមានដំណើរការប្រកបដោយប្រសិទ្ធភាពនៅផ្នែកអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត រួមមាន ការដាក់សំណើជាថ្មីដល់អង្គការសហប្រជាជាតិ សុំបុគ្គលិកចាំបាច់បន្ថែមទៀត ដើម្បីឲ្យមានលទ្ធភាពស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនៅក្នុងសំណុំរឿង ០០៣ និង ០០៤។

កាលពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ និង ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានដាក់កំណត់ហេតុចំនួនពីរស្តីពីការខ្វែងយោបល់ទាក់ទិននឹងកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ជូនអង្គបុរេជំនុំជម្រះ (វិធានផ្ទៃក្នុង ៧២)។ នៅក្នុងកំណត់ហេតុទាំងពីរ សហចៅក្រមស៊ើបអង្កេតជាតិ បានលើកឡើង ជាដំបូងយ៉ាងច្បាស់ ហើយក្រោយមកដោយប្រយោលអំពីការជំទាស់របស់ខ្លួន ចំពោះសំណើស្នើសុំឲ្យមានកិច្ចស៊ើបសួរទាំងនេះ។ មូលដ្ឋាននៃការជំទាស់នេះ គឺថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនទាន់បានតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ជាសហចៅក្រមស៊ើបអង្កេតពេញសិទ្ធិនៅឡើយ ដូច្នេះ គាត់គ្មានសិទ្ធិចាត់វិធានការទេ។

ប្រធានអង្គបុរេជំនុំជម្រះបានទទួលការខ្វែងយោបល់ទាំងនេះក្នុងថិរវេលាទាន់ពេល និងសមស្រប ហើយតាមរយៈអនុស្សរណៈចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ បានបញ្ជូនកំណត់ហេតុនៃការខ្វែងយោបល់ទាំងពីរនេះត្រឡប់វិញ ដោយមិនបានជូនដំណឹងថា អង្គបុរេជំនុំជម្រះបានធ្វើសេចក្តីសម្រេចមួយដោយមានសម្អាងហេតុឡើយ។ អនុស្សរណៈនេះ បានបញ្ជាក់ថា “ចៅក្រមនៃអង្គបុរេជំនុំជម្រះ”

បានជួបប្រជុំនៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ហើយ ចៅក្រមនៃអង្គបុរេជំនុំជម្រះ មិនបាន “ឯកភាពគ្នាដើម្បីធ្វើការពិចារណាទៅលើខ្លឹមសារនៃឯកសារទាំងនេះទេ” ដោយផ្អែកលើមូលដ្ឋានថា “លោក Laurent Kasper-Ansermet មិនមានលក្ខណៈសម្បត្តិចាំបាច់ដើម្បីបំពេញតួនាទីរបស់ខ្លួន ដោយអនុលោមតាមកិច្ចដំណើរការនីតិវិធីស្របច្បាប់ជាធរមានឡើយ”។

ដោយអនុលោមតាមច្បាប់សម្រាប់ដោះស្រាយការខ្វែងយោបល់គ្នា [មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ៧២(៤)(ឃ) ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចរកបាននូវសម្លេងគាំទ្រភាគច្រើនតាមការតម្រូវ ដីកា ឬ កិច្ចស៊ើបសួរដែលបានធ្វើឡើង (ឬដែលបម្រុងនឹងធ្វើ) ត្រូវមានសុពលភាព (ឬ ត្រូវតែយកមកអនុវត្ត)។ គោលការណ៍នេះត្រូវយកមកអនុវត្តយ៉ាងពេញលេញចំពោះការខ្វែងយោបល់ស្តីពីកិច្ចស៊ើបសួរ ដែលត្រូវបានស្នើសុំដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ដូច្នេះ សេចក្តីសម្រេចទាំងពីរ អាចយកមកអនុវត្តបាន។

ដោយផ្អែកលើមូលដ្ឋាននេះ នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាស្តីពីការបន្តធ្វើឡើងវិញនូវការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ (ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ)។

ច្បាប់តម្រូវឲ្យអង្គបុរេជំនុំជម្រះ ធ្វើការពិនិត្យលើកម្មវត្ថុនៃការខ្វែងយោបល់ និងចេញសេចក្តីសម្រេច “ដោយមានសម្អាងហេតុ និងដោយមានចុះហត្ថលេខារបស់អ្នកចេញសេចក្តីសម្រេច” [វិធានផ្ទៃក្នុង ៧២(៤)(ង)]។ ប្រធានអង្គបុរេជំនុំជម្រះ មិនបានឲ្យមានការជូនដំណឹងអំពីសេចក្តីសម្រេចនេះ តាមតម្រូវការនៃច្បាប់ដែលចែងពីនីតិវិធីទាំងនេះឡើយ។ ស្ថានភាពនេះបង្កឲ្យមានសេចក្តីព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរអំពីកង្វះនៃភាពអនាគតិរបស់លោក ប្រាក់ គឹម សាន ប្រធានអង្គបុរេជំនុំជម្រះ។ ដោយផ្អែកលើមូលដ្ឋានទាំងនេះ សំណើសុំដាក់បណ្តឹងជំទាស់ចំពោះចៅក្រម ប្រាក់ គឹមសាន ត្រូវបានដាក់ជូនអង្គបុរេជំនុំជម្រះ ដោយស្នើសុំឲ្យចៅក្រម ប្រាក់ គឹមសាន លាលែងដោយស្ម័គ្រចិត្តពីដំណើរការនីតិវិធីទាំងឡាយទាក់ទិននឹងសំណុំរឿង ០០៣ និង ០០៤។

ដើម្បីកែតម្រូវកំហុសនីតិវិធីដែលនាំឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានទទួលដំណឹងស្តីពីសេចក្តីសម្រេចលើការខ្វែងយោបល់ទាំងនេះ កំណត់ហេតុនៃការខ្វែងយោបល់ត្រូវបានបញ្ជូនត្រឡប់ទៅអង្គបុរេជំនុំជម្រះវិញ។